Press Release

# វិស័យកាត់ដេរសំលៀកបំពាក់នៅប្រទេសកម្ពុជា៖ ការងារធ្លាក់ចុះ ទោះបីជាការនាំចេញកើនឡើង នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់កម្ពុជា

សម្រាប់ចេញផ្សាយភ្លាមៗ៖ ថ្ងៃច័ន្ទ ទី២៩ ខែឧសភា ឆ្នាំ២០១៧ (ROAP/17/05)

**ភ្នំពេញ** – (ILO NEWS) – យោងតាមព្រឹត្តិបត្រព័ត៌មានចុងក្រោយបំផុតរបស់អង្គការអន្តរជាតិខាងការងារ ការងារនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់និងស្បែកជើងកម្ពុជា មានការធ្លាក់ចុះ បើទោះបីជាការនាំចេញទទួលបានលទ្ធផលល្អក្តី។

ការបោះពុម្ពផ្សាយលើកទីប្រាំមួយនៃព្រឹត្តិបត្រព័ត៌មានរបស់អង្គការអន្តរជាតិខាងការងារសម្រាប់វិស័យកាត់ដេរសំលៀកបំពាក់និងស្បែកជើងនៅកម្ពុជា បង្ហាញថា ខណៈដែលការនាំចេញបន្តកើនឡើងក្នុងល្បឿនដ៏រឹងមាំមួយក្នុងឆ្នាំ២០១៦ ដោយមានការកើនឡើងចំនួន ៧,២ភាគរយ ដល់ ៧,៣ ពាន់លានដុល្លារអាមេរិក តែចំនួននៃរោងចក្រនាំចេញដែលបានចុះបញ្ជីជាផ្លូវការក្នុងវិស័យនេះបានធ្លាក់ចុះចំនួន ១០,៤ភាគរយ ហើយចំនួនកម្មករបានធ្លាក់ចុះចំនួន ២,៩ភាគរយ ក្នុងឆ្នាំ២០១៦ បើប្រៀបធៀបនឹងឆ្នាំ២០១៥។

ការចេញផ្សាយចុងក្រោយបំផុតនៃព្រឹត្តិបត្រព័ត៌មានរបស់អង្គការអន្តរជាតិខាងការងារសម្រាប់វិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើងកម្ពុជា បានកំណត់កត្តាចម្បងបីដែលអាចរួមចំណែកដល់ភាពខុសគ្នារវាងការនាំចេញដែលមានលក្ខណៈរឹងមាំល្អ និងការធ្លាក់ចុះចំនួនការងារ និងការបង្កើតសហគ្រាសថ្មី។ កត្តាទាំងនេះរួមមាន៖

- ការកើនឡើងនូវផលិតភាព (Productivity) របស់ឧស្សាហកម្មនេះ
- បញ្ហាផ្នែកស្ថិតិទាក់ទងនឹងការវាស់វែងចំនួនការងារ និងចំនួនរោងចក្រ និង
- កំណើនផលិតកម្មនៅក្នុងរោងចក្រម៉ៅការបន្ត (Subcontracting factories)។

លោក ម៉ូរីហ្ស៊ីអូ ប៊ូស៊ី (Maurizio Bussi) នាយកការិយាល័យអង្គការអន្តរជាតិខាងការងារប្រចាំប្រទេស ថៃ កម្ពុជា និងឡាវ បានមានប្រសាសន៍ថា៖ "កំណើនការងារនិងផលិតកម្មនៅក្នុងរោងចក្រម៉ៅការបន្ត(Subcontracting factories) អាចជាការព្រួយបារម្ភមួយ ប្រសិនបើការម៉ៅការបន្តកំពុងត្រូវបានគេប្រើប្រាស់ជាវិធីមួយដើម្បីជៀសវាងច្បាប់និង ក្របខ័ណ្ឌគតិយុត្តិ រួមទាំងច្បាប់ការងារ និងប្រាក់ឈ្នួលអប្បបរមានោះ"។

មិនដូចជារោងចក្រនាំចេញដែលបានចុះបញ្ជីទេ អ្នកម៉ៅការបន្តមិនត្រូវបានត្រួតពិនិត្យតាមដានដោយកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជានោះទេ ហើយក៏អាចមានការយកចិត្តទុកដាក់ពីសំណាក់ស្ថាប័នអនុវត្តច្បាប់ជាតិ តិចជាងរោងចក្រធម្មតាដែរ។

លោក ប៊ូស៊ី បានបញ្ជាក់ថា៖ "ស្ថានភាពនេះគួរត្រូវបានតាមដានដោយប្រុងប្រយ័ត្នពីសំណាក់ភាគីពាក់ព័ន្ធ និងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា"។

**និន្នាការសំខាន់ៗផ្សេងទៀត**

ព្រឹត្តិបត្រព័ត៌មាន ក៏ផ្តល់ព័ត៌មានបច្ចុប្បន្នភាពផងដែរអំពីការវិវឌ្ឍថ្មីៗបំផុតនៅក្នុងវិស័យនេះ៖

- សំលៀកបំពាក់ និងស្បែកជើង នៅតែជាផលិតផលនាំចេញដ៏សំខាន់បំផុតរបស់កម្ពុជា ដែលតំណាងឱ្យប្រមាណ ៧៨ភាគរយនៃផលិតផលទំនិញនាំចេញសរុបរបស់ប្រទេសនេះក្នុងឆ្នាំ២០១៦។
- សហភាពអឺរ៉ុប (EU) នៅតែជាគោលដៅទីផ្សារសំខាន់បំផុតសម្រាប់ការនាំចេញផលិតផលសំលៀកបំពាក់ និង ស្បែកជើងរបស់កម្ពុជា ដោយសហរដ្ឋអាមេរិកស្ថិតក្នុងលំដាប់លេខពីរ។
- ការនាំចេញរបស់វិស័យនេះទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិករួមគ្នា តំណាងឱ្យប្រមាណតែ ៦៥ភាគរយប៉ុណ្ណោះក្នុងឆ្នាំ២០១៦ ធ្លាក់ចុះពី ៧២ភាគរយក្នុងឆ្នាំ២០១៥ ប៉ុន្តែមានកំណើនចំណែកទីផ្សារនៅក្នុងប្រទេសផ្សេងទៀតក្រៅពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ជាពិសេស ជប៉ុន និងកាណាដា។

ចំណូលប្រចាំខែជាមធ្យម (រួមទាំងប្រាក់ម៉ោងបន្ថែម) របស់កម្មករកាត់ដេរសំលៀកបំពាក់និងស្បែកជើងកម្ពុជា បានកើនឡើងពី ១៤៥ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤ ដល់ ១៧៥ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៥ និងដល់ ១៩៥ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៦។ បើគណនាសំរួលជាមួយអតិផរណា ប្រាក់ឈ្នួល/ចំណូលពិតប្រចាំខែមធ្យមក្នុងឆ្នាំ២០១៦ កើន៨,០ភាគរយ ខ្ពស់ជាងឆ្នាំ២០១៥។

*ព្រឹត្តិបត្រព័ត៌មាននេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងក្របខ័ណ្ឌនៃកម្មវិធី "និយាមការងារនៅក្នុងសង្វាក់ផ្គត់ផ្គង់សកល" ដែលផ្តល់មូលនិធិដោយក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហព័ន្ធ (BMZ) ក្នុងនាមរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

Matthew Cowgill
ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ - និយាមការងារនៅក្នុងសង្វាក់ផ្គត់ផ្គង់សកល
ការិយាល័យប្រចាំតំបន់នៃអង្គការអន្តរជាតិខាងការងារសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក បាងកក
Email: cowgill@ilo.org



*For information only. Not an official record.*